**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ផ្ញើជូន**

ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តម ជាទីស្រឡាញ់រាប់អាន

ខ្ញុំនិងភរិយា បានទទួលរួចហើយនូវលិខិតជូនសព្ទសាធុការពរបវរមហាប្រសើរ ដែលឯកឧត្តម និងថ្នាក់ដឹកនាំ មន្ត្រីរាជការ ព្រមទាំងបុគ្គលិក នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងឱកាសខួបគម្រប់ ៦៤ ឈានចូល ៦៥ ឆ្នាំ របស់ខ្ញុំ និងពរជ័យសិរីសួស្តីជ័យមង្គលទទួល អំណរបុណ្យចូលឆ្នាំថ្មីប្រពៃណី ជាតិ ឆ្នាំមមែ សប្តស័ក ព.ស ២៥៥៩ ដែលនឹងយាងមកដល់នាពេលដ៏ខ្លីខាងមុខនេះ ។

តបចំពោះពាក្យពេចន៍ពរជ័យពោរពេញដោយអត្ថន័យទូលំទូលាយស៊ីជម្រៅល្អប្រពៃថ្លៃថ្លានេះផងដែរ ខណៈនេះ ខ្ញុំនិងភរិយា សូមថ្លែងអំណរគុណដោយសមានចិត្តសោមនស្សរីករាយជាអនេកប្បការ និងសូមឧទ្ទិសបួងសួងដល់បុណ្យតេជះព្រះបារមីនៃវត្ថុស័ក្តិសិទ្ធទាំងអស់ក្នុងលោក ជាអាទិ៍ គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ព្រមទាំងឫទ្ធានុភាពទេវតារក្សា ឆ្នាំថ្មី **ព្រះនាមរាក្សសៈទេវី** សូមលោកអភិបាលគ្រងរក្សា ប្រោះព្រំព្រះពរជ័យសិរីមង្គលជូនឯកឧត្តម និងថ្នាក់ដឹកនាំ មន្ត្រីរាជការ ព្រមទាំងបុគ្គលិក នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺៈ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តម ទទួលនូវការគោរពស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅបំផុតពីខ្ញុំ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥*

**ហ៊ុន សែន**